០១.០៨.២៥
F0764
S.0825

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ....០០២.........អ.ស.ហ..ស.ស.ក

# សេចក្តីសម្រេច

## ស្តីពី

## ការកំណត់នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការស្នើសុំការឯកភាពរបស់និយ័តករសន្តិសុខសង្គម ក្នុងការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល រវាងស្ថាប័នប្រតិបត្តិករក្នុងប្រព័ន្ធសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលឯកជន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល



#១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
#168F, St. 598, Chrang Chamres 1, Russei Keo, Phnom Penh
Website: fsa.gov.kh, Telegram: t.me/fsacambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩០ ៧០០
Phone: (+855) 23 990 700
info@fsa.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១៣អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមនិវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៣៤អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១៦០អនក្រ.បក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២ ស្តីពីនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៩១ក.ប/ប្រ.ក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៧៣ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព
- បានឃើញប្រកាសអន្តរក្រសួងលេខ ៣២៧ក.ប./ប្រក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព
- យោងតាមតម្រូវការចាំបាច់របស់និយ័តករសន្តិសុខសង្គម

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ..**

សេចក្តីសម្រេចនេះ កំណត់អំពីនីតិវិធី និងលក្ខខណ្ឌតម្រូវនៃការស្នើសុំការឯកភាពពីនិយ័តករសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា ន.ស.ស. ក្នុងការចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល រវាងស្ថាប័នប្រតិបត្តិករក្នុងប្រព័ន្ធសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលឯកជន ដើម្បីបង្កើននូវតម្លាភាព និងគណនេយ្យភាពនៃការចុះកិច្ចព្រមព្រៀង និងពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសុខាភិបាល ជូនសមាជិកដែលបានចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និង/ឬ ផ្នែកហានិភ័យការងារ។

**ប្រការ២ ..**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះដំណើរការនៃការស្នើសុំចុះកិច្ចព្រមព្រៀងរវាងមូលដ្ឋានសុខាភិបាលឯកជន និង បេឡាជាតិសន្តិសុខសង្គម ដែលសរសេរជាអក្សរកាត់ថា ប.ស.ស. ដែលជាប្រតិបត្តិករក្នុងប្រព័ន្ធសន្តិសុខសង្គម។

**ប្រការ៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងសេចក្តីសម្រេចនេះ មាននិយមន័យដូចខាងក្រោម÷

១- **កិច្ចព្រមព្រៀង** សំដៅដល់នីតិវិធី និងបែបបទ នៃការផ្តល់សេវាសុខាភិបាលដោយមូលដ្ឋានសុខាភិបាលឯកជន និងការប្រើប្រាស់សេវាសុខាភិបាល របស់សមាជិក ប.ស.ស.

២- **សេវាសុខាភិបាល** សំដៅដល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព

៣- **មូលដ្ឋានសុខាភិបាលឯកជន** សំដៅដល់អង្គភាពព្យាបាលឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបានចុះកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលជាមួយប្រតិបត្តិករសន្តិសុខសង្គម។

## ជំពូកទី ២

## លក្ខខណ្ឌ និងនីតិវិធីក្នុងការចុះកិច្ចព្រមព្រៀងរវាង បេឡាជាតិសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលឯកជន

**ប្រការ៤ .-**

ប.ស.ស. ត្រូវចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជន ដែលមានលក្ខខណ្ឌដូចខាងក្រោម÷

- មានអាជ្ញាបណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល
- ត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតផ្តល់សេវា និងគុណភាពសេវាពី ប.ស.ស.
- ត្រូវទទួលបានការឯកភាពពី ន.ស.ស.។

**ប្រការ៥ .-**

ប.ស.ស. ត្រូវធ្វើការវាយតម្លៃមូលដ្ឋានសុខាភិបាលឯកជន ដែលបានដាក់ពាក្យស្នើសុំចុះកិច្ចព្រមព្រៀងប្រើប្រាស់ និងផ្តល់សេវាសុខាភិបាល ដោយអនុលោមតាមនីតិវិធីដូចបានកំណត់ក្នុង "ឯកសារណែនាំស្តីពីនីតិវិធីប្រតិបត្តិស្តង់ដា ដំណើរការចុះកិច្ចព្រមព្រៀងរវាងមូលដ្ឋានសុខាភិបាលឯកជនជាមួយបេឡាជាតិសន្តិសុខសង្គម" ជាធរមាន។

**ប្រការ៦ .-**

ប.ស.ស. អាចស្នើមក ន.ស.ស. សម្រាប់តែករណីដែលខ្លួនបានវាយតម្លៃរួចរាល់នូវមូលដ្ឋានសុខាភិបាលឯកជនដែលបានដាក់ពាក្យស្នើសុំមក ប.ស.ស. ប៉ុណ្ណោះ។

ការស្នើសុំ ត្រូវភ្ជាប់ជូននូវបញ្ជីនៃគ្រប់មូលដ្ឋានសុខាភិបាលឯកជន ដែលបានស្នើសុំចុះកិច្ចព្រមព្រៀងដោយបញ្ជាក់អំពីមូលដ្ឋានសុខាភិបាលឯកជនដែល ប.ស.ស. បដិសេធ ឬការស្នើសុំដកពាក្យស្នើសុំចុះកិច្ចព្រមព្រៀងដោយមូលដ្ឋានសុខាភិបាលផ្ទាល់។

**ប្រការ៧ .-**

ន.ស.ស. អាចបញ្ជូនមន្ត្រីទទួលបន្ទុក ចូលរួមសង្កេតលើរាល់ដំណាក់កាលនៃដំណើរការវាយតម្លៃលើមូលដ្ឋានសុខាភិបាលឯកជនដែលបានដាក់ពាក្យស្នើសុំចុះកិច្ចព្រមព្រៀងក្នុងការប្រើប្រាស់ និងផ្តល់សេវាសុខាភិបាលជាមួយ ប.ស.ស.។

ក្នុងករណីចាំបាច់ ន.ស.ស អាចបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីចុះពិនិត្យផ្ទាល់ដល់ទីតាំងមូលដ្ឋានសុខាភិបាលឯកជន ដោយមានការចូលរួមពីក្រុមការងារបច្ចេកទេសពាក់ព័ន្ធរបស់ ប.ស.ស.។

**ប្រការ៨ .-**

ប.ស.ស. ត្រូវរៀបចំ និងដាក់ការស្នើសុំការឯកភាពពី ន.ស.ស. ដោយភ្ជាប់នូវសំណុំឯកសារដូចមានចែងក្នុងប្រការ១៤ ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានបញ្ចប់ដំណាក់កាលចុះពិនិត្យ និងវាយតម្លៃលើទីតាំងមូលដ្ឋានសុខាភិបាលឯកជន។

**ប្រការ៩ .-**

ន.ស.ស. ត្រូវរៀបចំលិខិតឆ្លើយតប (ឯកភាព ឬបដិសេធ) ទៅ ប.ស.ស. ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានលិខិតស្នើសុំការឯកភាពដោយភ្ជាប់ជាមួយសំណុំឯកសារពេញលេញ ដូចមានចែងក្នុងប្រការ១៤ នៃសេចក្តីសម្រេចនេះ និងក្នុងករណីពិនិត្យឃើញថាលក្ខខណ្ឌទីតាំងមានភាពសមស្រប។

**ប្រការ១០ .-**

ប.ស.ស. ត្រូវស្នើសុំការឯកភាពជាមុនពី ន.ស.ស. ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ក្នុងករណីមានការកែសម្រួល ឬការបញ្ចប់កិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. និងត្រូវផ្តល់ជូន ន.ស.ស. នូវកិច្ចព្រមព្រៀងដែលបានចុះរួច និងឯកសារពាក់ព័ន្ធផ្សេងទៀតអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ១១ .-**

កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាង ប.ស.ស. និងមូលដ្ឋានសុខាភិបាលឯកជន ត្រូវមានសុពលភាពរយៈពេល ៣ (បី) ឆ្នាំ។

ប.ស.ស. ត្រូវជូនដំណឹងទៅមូលដ្ឋានសុខាភិបាលឯកជនឱ្យបានមុនរយៈពេល ៦០ (ហុកសិប) ថ្ងៃមុនពេលផុតសុពលភាព ដើម្បីរៀបចំនីតិវិធីចុះកិច្ចព្រមព្រៀងឡើងវិញ។

**ប្រការ១២ .-**

ប.ស.ស. ត្រូវធ្វើការវាយតម្លៃការផ្តល់សេវាសុខាភិបាលរបស់មូលដ្ឋានសុខាភិបាលឯកជន ដោយផ្អែកលើកិច្ចព្រមព្រៀង និងដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងត្រូវរាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃជូន ន.ស.ស. ជាប្រចាំ។

ន.ស.ស. អាចចេញសេចក្តីណែនាំស្តីពី ការវាយតម្លៃ សូចនាករពាក់ព័ន្ធនឹងការផ្តល់សេវាសុខាភិបាល តាមការចាំបាច់។

**ប្រការ១៣ ._**

ប.ស.ស. មិនត្រូវបានអនុញ្ញាតឱ្យបន្តចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលឯកជនទេ ក្នុងករណីរកឃើញថា មូលដ្ឋានសុខាភិបាលឯកជនមិនបានផ្តល់សេវាល្អជូនសមាជិក ប.ស.ស. ជាបន្តបន្ទាប់ ឬមានការកេងបន្លំធ្ងន់ធ្ងរលើការទូទាត់សេវាសុខាភិបាល អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣

## ឯកសារតម្រូវក្នុងការស្នើសុំការឯកភាពលើការចុះកិច្ចព្រមព្រៀង រវាង ប.ស.ស. និងមូលដ្ឋានសុខាភិបាលឯកជន

**ប្រការ១៤ ._**

ដើម្បីស្នើសុំការឯកភាព, ប.ស.ស. ត្រូវរៀបចំការស្នើសុំចុះកិច្ចព្រមព្រៀង និងដាក់ជូន ន.ស.ស. ដោយត្រូវភ្ជាប់នូវសំណុំឯកសារពាក់ព័ន្ធ ដូចខាងក្រោម÷

- ពាក្យស្នើសុំចុះកិច្ចព្រមព្រៀងផ្តល់សេវាសុខាភិបាលឯកជនផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារជាមួយ ប.ស.ស. (ច្បាប់ដើម)
- លិខិតចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានជាមួយ ប.ស.ស. (ច្បាប់ចម្លង)
- សេចក្តីសម្រេចស្តីពីការបើកសេវាសុខាភិបាលឯកជន (ច្បាប់ចម្លង)
- រចនាសម្ព័ន្ធរបស់សេវាសុខាភិបាលឯកជន (អង្គការលេខរបស់មូលដ្ឋានសុខាភិបាលឯកជន សញ្ញាបត្រឯកទេស សញ្ញាបត្រ និងវិញ្ញាបនបត្រ ឬលិខិតបញ្ជាក់ការសិក្សា)
- គំនូសបំព្រួញទីតាំងសេវាសុខាភិបាលឯកជន និង ទីតាំងក្នុង Google Map
- លិខិតថ្កោលទោសរបស់ប្រធានមូលដ្ឋានសុខាភិបាលឯកជន (ច្បាប់ចម្លង)
- វិញ្ញាបនបត្រ ចេញដោយក្រសួងសុខាភិបាល
- បញ្ជីផ្ទៀងផ្ទាត់ស្តង់ដាអប្បបរមាសម្រាប់មូលដ្ឋានសុខាភិបាលឯកជន ដែលបានបំពេញរួច
- កំណត់ហេតុ ឬរបាយការណ៍វាយតម្លៃ
- របាយការណ៍ចុះត្រួតពិនិត្យមូលដ្ឋានសុខាភិបាលឯកជន ដែលស្នើសុំចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ក្នុងករណីមានការចុះវាយតម្លៃ
- សេចក្តីព្រាងកិច្ចព្រមព្រៀង ដែលត្រូវចុះរវាងមូលដ្ឋានសុខាភិបាលឯកជន និង ប.ស.ស. និង
- ឯកសារពាក់ព័ន្ធផ្សេងទៀត ដែលអាចតម្រូវដោយ ន.ស.ស.។



ℤ

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**ប្រការ១៥ ..**

អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករ និងប្រធានអង្គភាព ក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ថ្ងៃសុក្រ ១៣ កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មិថុ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព និងសមាសភាពក្រុមប្រឹក្សានៃ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ដូចប្រការ ១៥
"ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ